អន្តរប្រិ៍យ
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ៖ តើរាជរដ្ឋាភិបាលខ្មែរមានអ្វីជាគោលអាង ដែលគួរជឿទុកចិត្តថា ការបោះបង្គោលព្រំដែនរវាងកម្ពុជា-វៀតណាមមានភាពត្រឹមត្រូវ ?

**Website: www.hoksavann.org**

ថ្ងៃទី១១ មិថុនា ២០១០



គណបក្សប្រឆាំងតែងចោទប្រកាន់រាជរដ្ឋាភិបាលថា ការបោះបង្គោលព្រំដែនកម្ពុជា-វៀតណាម ធ្វើឲ្យខ្មែរបាត់បង់ទឹកដី ចំណែករាជរដ្ឋាភិបាលតែងឆ្លើយថា ការបោះបង្គោលនេះមិនបានធ្វើឲ្យខ្មែរបាត់បង់ទឹកដីទេ គឺមានតែបានចំណេញថែមទៀត ។

នៅខែឧសភាឆ្នាំ២០១០នេះ ប្រជាពលរដ្ឋខ្មែរនៅភូមិបូរីជលសា ខេត្តតាកែវ បានស្រែកថា ដីស្រែរបស់ខ្លួនបានត្រូវបាត់បង់ដោយវៀតណាមបានបោះបង្គោលចូលមកដីរបស់ខ្លួន ត្រង់បង្គោលលេខ២៧០ ។ មួយទៀត កាលពីថ្ងៃទី២៥ តុលា ២០០៩ តុលាការនៅខេត្តស្វាយរៀងបានកាត់ទោសកំបាំងមុខចំពោះគណបក្សប្រឆាំង និងកាត់ទោសប្រជាពលរដ្ឋពីរនាក់ឲ្យជាប់ពន្ធនាគារដោយចោទថា បានដកបង្គោលតម្រុយព្រំដែន ដែលបង្គោលនោះប្រជាពលរដ្ឋបានចោទថា បានបោះចូលមកដីស្រែរបស់ខ្លួន ។

តាមគំរោងការរបស់កម្ពុជា-វៀតណាមថា ចំនួនបង្គោលដែលបានបោះទាំងអស់៣៧៥ ក្នុងបណ្តោយព្រំដែនកម្ពុជា-វៀតណាមប្រវែង១,២៧០គ.ម. ហើយត្រូវបោះឲ្យរួចចប់សព្វគ្រប់នៅឆ្នាំ២០១២ ។ តាមពត៌មានថា បង្គោលដែលបានបោះរួចហើយមានចំនួន១៨០ ។ ប្រជាពលរដ្ឋខ្មែរមានការសង្ស័យថា តើបង្គោលដែលបានបោះរួចហើយ ដែលបានចាក់បេតុងយ៉ាងរឹងមាំនោះ មានភាពត្រឹមត្រូវឬទេ ? ព្រោះភស្តុតាងគ្រាន់តែបង្គោលពីរ គឺបង្គោលលេខ១៨៥ នៅស្រុកចន្ទ្រា ខេត្តស្វាយរៀង និងបង្គោលលេខ២៧០ នៅស្រុកបូរីជលសា ខេត្តតាកែវ ប្រជាពលរដ្ឋស្រែកតវ៉ាថា ថាបានបោះចូលមកក្នុងដីស្រែរបស់ខ្លួន ។ បង្គោលដែលបានបោះរួចហើយទាំង១៨០ អាចបោះចូលមកដីខ្មែរតាមព្រៃដែលគ្មានប្រជាពលរដ្ឋរស់នៅ និងកន្លែងខ្លះបានបោះចូលមកដីស្រែរបស់កសិករខ្មែរ ប៉ុន្តែប្រជាពលរដ្ឋខ្មែរខ្លះមិនហ៊ានស្រែកតវ៉ា ព្រោះខ្លាចអាជ្ញាធរខ្មែរ ដូចករណីកសិករខ្មែរពីរនាក់នៅស្រុកចន្ទ្រា ខេត្តស្វាយរៀងត្រូវជាប់ពន្ធនាគារ ។ ប្រជាពលរដ្ឋខ្មែរគួរមានសេចក្តីក្លាហាន ប្រកាសប្រាប់ឲ្យគេឯងដឹងពូនូវទឹកដីរបស់ខ្លួន ដែលត្រូវបាត់បង់ដោយសារការបោះបង្គោលព្រំដែននេះ ហើយបើប្រជាពលរដ្ឋណាបានឃើញបង្គោលព្រំដែនបានបោះចូលមកដីខ្មែរតាមព្រៃ ឬស្ទឹងទន្លេបឹងបួរ ក៏គប្បីប្រកាសប្រាប់ដូចគ្នា ។ ការបោះបង្គោលព្រំដែននេះពូសូរតែចូលដីខ្មែរ មិនពូសូរចូលដីរបស់ប្រទេសវៀតណាម ដែលនាំឲ្យប្រជាពលរដ្ឋវៀតណាមស្រែកតវ៉ាសោះ ។ ត្រង់នេះហើយដែលប្រជាពលរដ្ឋខ្មែរមានការសង្ស័យអំពីភាគីវៀតណាមមានប្រៀបមកលើភាគីខ្មែរ ទាំងល្បិចកិច្ចកលទាំងអ្នកបច្ចេកទេសក្នុងការវាស់វែងព្រំដែននេះ សមនឹងវៀតណាមសុខចិត្តចេញចំណាយទាំងអស់ក្នុងការបោះបង្គោលព្រំដែននេះផង ។ សង្ស័យមួយទៀត ត្រង់សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ មិនដឹងជាមានអាថ៌កំបាំងបែបណា ដែលមិនបានប្រកាសប្រាប់ប្រជាពលរដ្ឋខ្មែរឲ្យដឹងត្រង់ចំណុចអាថ៌កំបាំងនោះ ។ បានជាប្រជាពលរដ្ឋខ្មែរយកចិត្តទុកដាក់អំពីបញ្ហាបាត់បង់ទឹកដីនេះ ព្រោះវាជាអាយុជីវិតរបស់ប្រទេស សូមឲ្យរាជរដ្ឋាភិបាលយោគយល់អំពីបញ្ហានេះ ។ រាជរដ្ឋាភិបាលអាចឆ្លើយថា រាជរដ្ឋាភិបាលដែលកើតអំពីការបោះឆ្នោត មានការទុកចិត្តពីប្រជាពលរដ្ឋ តំណាងប្រជាពលរដ្ឋហើយ រាជរដ្ឋាភិបាលប្តេជ្ញាថានឹងថែរក្សាទឹកដីខ្មែរសូម្បី១មីល្លីម៉ែត្រក៏មិនឲ្យបាត់ដែរ ។ ប្រទេសកាន់របបប្រជាធិបតេយ្យនឹងឆ្លើយតបថា រដ្ឋាភិបាលមិនអាចធ្វើត្រឹមត្រូវសព្វគ្រប់មិនខុសឡើយ ដូច្នេះហើយបានជាមានស្ថាប័នដទៃទៀតតាមដានពិនិត្យមើលសកម្មភាពរបស់រដ្ឋាភិបាល គឺរដ្ឋសភានិងព្រឹទ្ធសភា ហើយបើកឲ្យប្រជាពលរដ្ឋបញ្ចេញមតិតាមរយៈការធ្វើបាតុកម្ម កូដកម្មថែមទៀត ។ រាជរដ្ឋាភិបាលអាចឆ្លើយថា ឥឡូវនេះរដ្ឋសភានិងព្រឹទ្ធសភាយល់ស្របថា ការវាស់វែងព្រំដែននេះត្រឹមត្រូវហើយ ។ ប្រជាពលរដ្ឋអាចឆ្លើយតបទៅវិញថា រដ្ឋសភានិងព្រឹទ្ធសភាខ្មែរគ្មានពូថា ទៅពិនិត្យមើល ឬឲ្យអ្នកបច្ចេកទេសទៅពិនិត្យមើលឲ្យបានហ្មត់ចត់ថា ការវាស់វែងទាំងនោះត្រឹមត្រូវឬមិនត្រឹមត្រូវឡើយ ។ ភស្តុតាងគេឃើញរដ្ឋសភាប្រជុំម្តងៗអំពីបញ្ហាអ្វីមួយ សមាជិកសភារបស់គណបក្សប្រជាជនកម្ពុជាចំនួន៩០រូប គ្មានឃើញឡើងបញ្ចេញមតិរិះគន់សំណើរបស់រាជរដ្ឋាភិបាលត្រង់ចំណុចណាមួយឡើយ បើឡើងនិយាយគ្មានអ្វីក្រៅពីពោលសរសើររាជរដ្ឋាភិបាល ដោយរង់ចាំតែលើកដៃអនុម័តយល់ព្រមតែប៉ុណ្ណោះ ព្រោះហាក់ដូចជាសំណើនោះ រាជរដ្ឋាភិបាលនិងរដ្ឋសភាបាននិយាយគ្នាសម្ងាត់ក្រៅផ្លូវការរួចទៅហើយ ទោះបីគណបក្សប្រឆាំងមានយោបល់ជំទាស់យ៉ាងណាក៏គ្មានបានការអ្វីឡើយ ដូច្នេះការប្រជុំពិភាក្សាគ្នានោះ ហាក់ដូចជាគ្រាន់តែធ្វើឡើងដើម្បីបង្គ្រប់កិច្ចប៉ុណ្ណោះ ។ ដោយរដ្ឋសភាខ្មែរមិនបានបំពេញឲ្យគ្រប់លក្ខណៈតាមមុខងាររបស់ខ្លួននេះហើយ បានជាប្រជាពលរដ្ឋមិនទុកចិត្ត អំពីការត្រួតពិនិត្យមើលបញ្ហាវាស់វែងបង្គោលព្រំដែននេះ ។ ដូច្នេះប្រជាពលរដ្ឋខ្មែរជាម្ចាស់អំណាចក៏បញ្ចេញមតិអំពីបញ្ហាការវាស់វែងព្រំប្រទល់ដែននេះ ព្រោះខ្លាចបាត់បង់ទឹកដី ។ សូមរាជរដ្ឋាភិបាលគោរពរដ្ឋធម្មនុញ្ញត្រង់មាត្រាសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការបញ្ចេញមតិ កុំរករឿងប្រជាពលរដ្ឋប្តឹងឡើងតុលាការ ដែលជាតុលាការគ្មានឯករាជ្យ ចាប់ប្រជាពលរដ្ឋដាក់ពន្ធនាគារដូចមានកន្លងមកហើយ នៅស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

ដូចបានពោលមកហើយ តើរាជរដ្ឋាភិបាលខ្មែរបង្ហាញភស្តុតាងបែបណាដែលបញ្ជាក់ថា ការវាស់វែងបោះបង្គោលព្រំដែនកម្ពុជា-វៀតណាមមានភាពត្រឹមត្រូវ ។ ព្រោះការបោះបង្គោលកន្លងមកហើយ ត្រូវប្រជាពលរដ្ឋខ្មែរស្រែកតវ៉ាថា ពុំ

ត្រឹមត្រូវដោយបោះចូលមកដីរបស់ខ្លួន ហើយអ្នកដទៃទៀតដែលពុំមែនជាម្ចាស់ដី ក៏ឃើញថាបង្គោលទាំងនោះបានបោះឃ្លាតចេញពីព្រំប្រទល់ដែន ចូលមកដីកសិករខ្មែររាប់រយម៉ែត្រ ។ ចំណែកគណបក្សប្រឆាំងបានបង្ហាបច្ចេកទេសមួយ ដែលមានអ្នកឯកទេសដ៏ល្បីឈ្មោះ ជួយផ្តល់យោបល់ក្នុងការវាស់វែងព្រំប្រទល់ដែនផង តែត្រូវរាជរដ្ឋាភិបាលច្រានចោល ថែមទាំងរករឿងប្តឹងថែមទៀត ។ ដូច្នេះដើម្បីបញ្ជាក់ថា វិធានការរបស់រាជរដ្ឋាភិបាលក្នុងការវាស់វែងព្រំប្រទល់ដែននិងការបោះបង្គោលនេះមានភាពត្រឹមត្រូវ លុះត្រាតែមានអ្នកទីបីមានជំនាញការអន្តរជាតិខាងការវាស់វែងព្រំប្រទល់ដែននេះបញ្ជាក់ ឬក៏សំរបសំរួលគ្នាបែបណាឲ្យឃើញការពិត ដើម្បីជៀសវាងការចោទប្រកាន់គ្នាទៅវិញទៅមក ទុកជាការបង្រួបបង្រួមជាតិ ហើយសំខាន់បំផុតជៀសវាងខ្មែរបាត់បង់ទឹកដី ។

ចំពោះតួនាទីរបស់ព្រះមហាក្សត្រ ក្នុងមាត្រា៨នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា ៖ «ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា» ។ ព្រះមហាក្សត្រធានាមិនឲ្យខ្មែរបាត់បង់ទឹកដីនេះ តើធានាបែបណា ? ។ បើធានាទាល់តែមានការការពារ ។ បើការពារបានលុះត្រាតែបញ្ចេញសកម្មភាពការពារដោយហោចណាស់ក៏ឲ្យយោបល់ដល់រាជរដ្ឋាភិបាលបែបណាមួយ ដើម្បីការពារទឹកដីនេះ ។ បើធានាការពារ ប៉ុន្តែនៅស្ងៀមមិនបញ្ចេញសកម្មភាពអ្វីសោះ ទោះបីបរទេសរំលោភយកទឹកដីក៏ដោយ មិនឈ្មោះថាធានាឡើយ ។ ឬមួយសង្ឃឹមលើរាជរដ្ឋាភិបាល ចុះបើរាជរដ្ឋាភិបាលប្រព្រឹត្តខុសរហូតឲ្យខ្មែរបាត់បង់ទឹកដី តើព្រះមហាក្សត្រទទួលខុសត្រូវផងឬទេ ? ត្រង់មាត្រា៧នៃរដ្ឋធម្មនុញ្ញចែងថា ៖ «ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ» ។ ត្រង់មាត្រា៧នេះហើយដែលទ្រង់ស៊ីសុវត្ថិ-ធម្មិកោឆ្លើយតបរបៀបវាយប្រហារទៅខ្មែរកម្ពុជាក្រោមនិងគណបក្សប្រឆាំង ដែលសុំឲ្យព្រះអតីតព្រះមហាក្សត្រខ្មែរ ដែលនឹងយាងទៅធ្វើទស្សនកិច្ចនៅប្រទេសវៀតណាមនៅពេលឆាប់ៗនេះ ដោយសុំឲ្យព្រះអង្គលើកយកការរំលោភសិទ្ធិរបស់វៀតណាមមកលើខ្មែរកម្ពុជាក្រោម និងបញ្ហាទឹកដីនៅតាមព្រំដែនកម្ពុជា-វៀតណាម ទៅពិភាក្សាជាមួយវៀតណាម ។ យើងយល់ថា ព្រះអតីតព្រះមហាក្សត្រខ្មែរមានសិទ្ធិធ្វើសំណូមពរដល់វៀតណាមដែលជាមិត្តចាស់របស់ព្រះអង្គ នូវគ្រប់បញ្ហាដែលមានប្រយោជន៍ដល់ខ្មែរ ក្នុងឋានៈព្រះអង្គជាកុលបុត្រខ្មែរមួយព្រះអង្គ ទ្រង់ស៊ីសុវត្ថិ-ធម្មិកោមិនអាចបិទព្រះឱស្ឋព្រះអង្គបានឡើយ ។៚